# តើជំងឺ COVID-19 គឺជាអ្វី?



## តើជំងឺ COVID-19 គឺជាអ្វី?

ជំងឺ COVID-19 គឺបណ្ដាលមកពីមេរោគ SARS-CoV-2។ វាចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតភាគច្រើនតាមរយៈខ្យល់។ មនុស្សជាច្រើនមានរោគសញ្ញាស្រាល ឬក៏គ្មានរោគសញ្ញាតែម្ដង ប៉ុន្តែជំងឺ COVID-19 ក៏អាចបណ្ដាលឱ្យធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ និងស្លាប់ផងដែរ។ មនុស្សអាចចម្លងមេរោគនេះ ទោះបីពួកគេមិនមានរោគសញ្ញាក៏ដោយ។

## តើមានរោគសញ្ញាអ្វីខ្លះ?

រោគសញ្ញាជំងឺ COVID-19 ជារឿយៗមានអារម្មណ៍ថាអ្នកមានជំងឺផ្ដាសាយ ឬគ្រុនផ្ដាសាយធំ។ មនុស្សមួយចំនួនដែលមានជំងឺ COVID-19 មិនមានអារម្មណ៍ថាឈឺនោះទេ។

រោគសញ្ញាទូទៅរួមមាន៖

- លែងដឹងរសជាតិ ឬក្លិន
- ក្អក
- បញ្ហាដកដង្ហើម
- គ្រុនក្ដៅ ឬគ្រុនរងា
- អស់កម្លាំង
- ឈឺសាច់ដុំ ឬឈឺខ្លួន
- ឈឺបំពង់ក
- តឹងច្រមុះ ឬហៀរសំបោរ
- ចង្អោរចង់ក្អួត ឬក្អួត
- រាគរូស



ជំងឺ COVID-19 ក៏អាចបណ្ដាលឱ្យមានរោគសញ្ញាផ្សេងទៀតផងដែរ។

## ជំងឺ COVID រយៈពេលយូរ

មនុស្សមួយចំនួនរងគ្រោះពីរោគសញ្ញាថ្មី ឬបន្តមានរោគសញ្ញារយៈពេលជាច្រើនសប្ដាហ៍ ឬច្រើនខែបន្ទាប់ពីឆ្លងជំងឺ COVID-19។ រោគសញ្ញានេះត្រូវបានគេស្គាល់ថាជាជំងឺ COVID រយៈពេលយូរ ឬជំងឺក្រោយ COVID។ វាអាចរាប់បញ្ចូលទាំងមនុស្សដែលមិនមានរោគសញ្ញា ឬរោគសញ្ញាស្រាលនៅពេលពួកគេបានឆ្លងមេរោគ។

ជំងឺ COVID-19 រយៈពេលយូររួមបញ្ចូលទាំងរោគសញ្ញាជាច្រើនប្រភេទ ដែលរួមមានការអស់កម្លាំង ឈឺក្បាល ឈឺសន្លាក់ឬសាច់ដុំ ការផ្លាស់ប្ដូរអារម្មណ៍ឬដំណេក រោគសញ្ញាផ្លូវដង្ហើម និងការពិបាកក្នុងការគិត។

## តើអ្នកណាដែលប្រឈមនឹងហានិភ័យបំផុតនោះ?

- មនុស្សពេញវ័យ និងកុមារដែលមិនបានចាក់ថ្នាំបង្ការពេញលេញ ប្រឈមនឹងហានិភ័យខ្លាំងបំផុតក្នុងការឆ្លងជំងឺ COVID-19។
- មនុស្សពេញវ័យដែលមិនបានចាក់ថ្នាំបង្ការដែលមានអាយុច្រើន ឬមានបញ្ហាសុខភាពជាក់លាក់គឺប្រឈមនឹងហានិភ័យខ្លាំងបំផុតចំពោះការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរនិងស្លាប់ដោយសារជំងឺ COVID-19។





COUNTY OF LOS ANGELES Public Health